ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

របាយការណ៍
ស្តីពី
សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត

I- សភាពការណ៍រួម

នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៧នេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៩៩,៩៩%និងការងារ ប្រមូលផលដំណាំរដូវប្រាំងបានបញ្ចប់ជាស្ថាពរហើយ។ ជាពិសេសការបង្កបង្កើនផលស្រូវរដូវប្រាំងរួមទាំងដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មផងដែរ។ ជាការកត់សម្គាល់ ការប្រើប្រាស់ដោយគ្រឿងយន្តសម្រាប់ផលិតកម្មកសិកម្មកំពុងមាននិន្នាការកើនឡើង ៩១,១៧% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របី ៨,៨៣% ដែលជាបច្ចុយមួយបង្ហាញអំពីដំណើរការវិវឌ្ឍន៍នៃយន្តូបនីយកម្មកសិកម្ម។ ទន្ទឹមនឹងនោះថ្នាក់ដឹកនាំក្រសួងរួមទាំងអង្គភាពជំនាញដែលជាសេនាធិការបានចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួងយ៉ាងសកម្ម ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្មដែលនាំឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្ម។ ទន្ទឹមនឹងនេះក៏ទទួលជួបសវនាការជាមួយអង្គទូត និងដៃគូអភិវឌ្ឍន៍តាមវិស័យនីមួយៗរួមទាំងការចូលរួមកិច្ចប្រជុំសំខាន់ៗ ការរៀបចំសិក្ខាសាលាវគ្គបណ្តុះបណ្តាលផ្សេងៗទាំងក្នុង និងក្រៅប្រទេសជាច្រើនផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ២០១៧នេះ មានដូចតទៅ៖

II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

១ ផ្នែកដាំដុះ

១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៥៧៦ ៦៤០ហ.ត លើសឆ្នាំមុនចំនួន ៤២ ៨៦២ហ.ត ក្នុងនោះភ្ជួររាស់ដោយគោក្របីមានចំនួន ១៨ ១៩៧ហ.ត ស្មើនឹង២,៤៦% និងដោយគ្រឿងយន្តមានចំនួន ៥៦២ ៤៤៣ហ.ត ស្មើនឹង៩៧,៥៤%
- ផ្ទៃដីសាបសម្រេចបានចំនួន ៥៥៦ហ.ត តិចជាងឆ្នាំមុនចំនួន ៦០៧ហ.ត
- ផ្ទៃដីសន្ធូង និងព្រោះសម្រេចបានចំនួន ៥១៨ ៥៧៨ហ.ត ស្មើនឹង ១១៩,៥៥% នៃផែនការ ៤៣៣ ៧៥៥ហ.ត លើសឆ្នាំមុនចំនួន ២៩ ១១៩ហ.ត

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- ការងារប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៥១៨ ៥១៨ហ.ត ស្មើនឹង៩៩,៩៩% លើផ្ទៃដីអនុវត្តចំនួន ៥១៨ ៥៧៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ២ ៣១៥ ៣៦៤តោន លើសឆ្នាំមុន ១៥០ ៧៦៤ តោន។ ទិន្នផលគិតជាមធ្យមទទួលបាន ៤,៤៦៥តោន/ហ.ត លើសឆ្នាំមុន ៤៣គ.ក្រ/ហ.ត។

១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំង

ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១១២ ២៣០ហ.ត តិចជាងឆ្នាំមុនចំនួន ៧ ០៧០ ហ.ត ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៩៧ ៤៦៧ហ.ត ស្មើនឹង ១២១,០៩% នៃផែនការ ៨០ ៤៩៤ហ.ត លើសឆ្នាំមុនចំនួន ៧ ០០១ហ.ត

- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១៤ ៧៦៣ហ.ត ស្មើនឹង ១០៣,៨៩% នៃផែនការ ១៤ ២១០ហ.ត តិចជាងឆ្នាំមុនចំនួន ៦៩ហ.ត។

១.៣ ការនាំចេញអង្ករ

ក្នុងត្រីមាសទី១ ឆ្នាំ២០១៧នេះ ការនាំអង្ករចេញកាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ១៦៦ ៦៧៨ តោន ដែលមានការកើនឡើងចំនួន ៤ ៤៥៨តោន (+៣%) ធៀបនឹងបរិមាណនាំចេញក្នុងរយៈពេលត្រីមាសទី១ ឆ្នាំ២០១៦។ កំណើនក្នុងខែមករា ឆ្នាំនេះធៀបនឹងខែមករាឆ្នាំមុនមាន១០,៩% និងកំណើនក្នុងខែកុម្ភៈឆ្នាំនេះធៀបនឹងខែកុម្ភៈឆ្នាំមុនមាន១៧%។ ផ្ទុយទៅវិញ ក្នុងខែមីនាឆ្នាំនេះ ធៀបនឹងខែមីនាឆ្នាំមុនមានការថយចុះរហូតដល់-១៦% ហើយក៏ជាបរិការណ៍មួយក្នុងកាលៈទេសៈដែលយើងកំពុងប្រឈមទល់នឹងការចាប់ផ្តើមអនុវត្តនីតិវិធីថ្មីរបស់សហភាពអឺរ៉ុប នៅដើមខែកក្កដា ឆ្នាំ២០១៧ ខាងមុខនេះ នូវការកំណត់មិនឲ្យមានសំណល់ថ្នាំកសិកម្ម Tricyclazole លើសពី0,01 មីលីក្រាមក្នុង ១គីឡូក្រាមអង្ករ។ បរិមាណនាំចេញក្នុងខែមីនានេះ បាននាំចេញទៅកាន់ទិសដៅចំនួន ៥៣ប្រទេស ក្នុងនោះ ប្រទេសចិនឈរលំដាប់ទី១ (៦៧ ៤៩២តោន) ប្រទេសបារាំងឈរលំដាប់ទី២ (២១ ០០៦តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៣ (១២ ៩១៤តោន) ប្រទេសអង់គ្លេសឈរលំដាប់ទី៤ (១០ ៦៧១តោន) ប្រទេសនីដឺឡែនឈរលំដាប់ទី៥ (៧ ៦៥០តោន) ប្រទេសឆេកឈរលំដាប់ទី៦ (៦ ០០៥តោន) ប្រទេសបែលហ្ស៊ិកឈរលំដាប់ទី៧ (៥ ៧៩៨តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៨ (៤ ៤៥១តោន) ប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី៩ (៣ ៤៩៨តោន) និងប្រទេសអេស្ប៉ាញឈរលំដាប់ទី១០ (២ ២៧១តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៦៣ក្រុមហ៊ុន។ ទន្ទឹមនឹងនេះ ក្រសួងក៏បានចេញសេចក្តីណែនាំ លេខ២៦៤៥ កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីបញ្ឈប់ការនាំចូល ផ្គត់ផ្គង់ចែកចាយ និងប្រើប្រាស់ថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Tricyclazole ។

២ ផ្នែកកៅស៊ូ

២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

ល.រ	អង្គភាព	ផ្ទៃដីអាជីវកម្ម (ហ.ត)	ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត)	ផលិតផលអនុវត្តបានប្រចាំខែនេះ (តោន)	បញ្ជាញ្ញលក់ប្រចាំខែនេះ(តោន)
I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ					
១	វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា	៥៨៣	៧៧៦	១៦១	១០០
	សរុប I	**៥៨៣**	**៧៧៦**	**១៦១**	**១០០**
II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន					
១	ក្រុមហ៊ុន សុកត្ថិនីកា អ៊ិនវេសមេន គ្រុប	១១ ៩៥៧	១៥ ៣៨២	៨ ៨១២	១ ៣៧៨
២	ក្រុមហ៊ុន ស្វីហ្ស៉ាប់ប៊ើ លីមីធីត (រតនគីរី)	៧៩	២ ៥៥៨	១៩	-
៣	ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ	៩៩០	២ ១០១	៣៣៨	84
៤	ក្រុមហ៊ុន ឡុង ស្រេង	៥ ៦៣៨	៨ ៧៤៤	១ ២៧៩	៧០២
៥	ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអ៊ិលធីឌី	៣ ៩៩៧	៨ ៦៦១	១ ០០៥	៥០០

៦	ក្រុមហ៊ុន ស្វីហ្ការីសសស៍ (ស្ពួល)	១ ៨៩១	៨ ៥១២	៩២៦	៥៧៨
៧	ក្រុមហ៊ុនអានម៉ាឌីគ្រុប (ពាមជាំង រមាសហែ)	១ ៨៨២	៣ ៣៩០	២៥៦	១៧០
៨	ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង)	៣ ៣២៧	៥ ៩២៤	៤៣៨	៣២០
៩	ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអ៊ិលធីឌី	៤ ០៣៥	៥ ៧៣១	១ ១៥៤	១ ០០៨
	សរុប ii	**៣៣ ៧៩២**	**៥៧ ០០៣**	**១០ ២២៧**	**៤ ៧៣៦**
iii-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ					
១១	ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច	៨ ៩៦០	២២៣ ៧៥៨	៧ ១០០	៥ ២០០
១២	ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ	៨៦ ៣៣១	១៥៤ ៤៥៤	១៩ ៣០០	១៤ ៥០០
	សរុប iii	**៩៥ ២៩១**	**៣៧៨ ២១២**	**២៦ ៤០០**	**១៩ ៧០០**
	សរុប i+ii+iii	**១២៩ ៦៦៦**	**៤៣៥ ៩៩១**	**៣៦ ៧៨៨**	**២៤ ៥៣៦**

- គួរកត់សម្គាល់ថា សម្រាប់ខែមីនា ឆ្នាំ២០១៧នេះ តម្លៃកៅស៊ូជាមធ្យម ២ ០២៨ដុល្លារក្នុងមួយតោន។

២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានរៀបចំទីតាំងស្រង់ទិន្នន័យជំងឺ Oidium នៅចម្ការកៅស៊ូក្រែក
- ធ្វើជំរឿនសម្ភារ ឧបករណ៍ និងសារធាតុគីមីមន្ទីរពិសោធន៍ជីវគីមីនិងសរីរវិទ្យា
- ជំរឿនកូនកៅស៊ូងាប់ក្នុងឡូត៍ពិសោធន៍ IRAA012 និងច្បារពូជប្លូត២១
- បានរៀបចំអត្ថបទស្រាវជ្រាវឥទ្ធិពលអ៊ីដ្រុកស៊ីលអាមីនស៊ុលផាតណីត លើកៅស៊ូសន្លឹក
- ត្រួតពិនិត្យលើផ្ទាំងមុខចៀរ និងលាបថ្នាំរំញោចដើមកៅស៊ូ
- បានបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូស្តីពី ការគ្រប់គ្រងច្បារពូជនិងថ្នាលបណ្តុះកូនកៅស៊ូដល់ប្រជាកសិករនៅស្រុកកំចាយមារ ខេត្តព្រៃវែង
- បានបណ្តុះបណ្តាលបច្ចេកទេសកៅស៊ូស្តីពី ការដាំដុះនិងថែទាំកៅស៊ូ ដល់កសិករនៅខេត្តត្បូងឃ្មុំ
- បានចុះពិនិត្យ និងវាយតម្លៃច្បារពូជកៅស៊ូនៅស្រុកស្ទឹងត្រែង ខេត្តកំពង់ចាមបានចំនួន០៨ច្បារពូជ សរុបចំនួន ២៤ ៦៣៦គល់ពូជ
- ចុះប្រមូលទិន្នន័យ និងវាស់ទំហំដើមតាមដានការលូតលាស់ចម្ការកៅស៊ូក្រែក
- បានបំបៅកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០១៦-២០១៧
- ថែទាំសមូហកម្មពូជដំណាំគម្របដីចំនួន ១៧ប្រភេទ និងថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៦-២០១៧
- ត្រួតពិនិត្យទូទៅលើការថែទាំច្បារពូជកៅស៊ូ និងស្រង់ទិន្នន័យជ័ររកៅស៊ូឡូត៍ពិសោធន៍ IRAA01-IRAA09
- ធ្វើតេស្តភាគសំណាកយថាប្រភេទចំនួន ០៩ភាគសំណាក សម្រាប់ធ្វើតេស្តត្រួតពិនិត្យគុណភាពរោងចក្រ
- បានសហការជាមួយអង្គការ UNIDO ដើម្បីពិនិត្យស្ថានភាពឧបករណ៍ជំនួយ
- វិភាគ DRC តាមមេត្រូឡាក់ តាមការដុតរក TSC និងការវិភាគតាមមន្ទីរពិសោធន៍
- បានជួត់ផ្ទងអង្ករ ទឹក អគ្គិសនី និងបៀវត្សរ៍ជូនកម្មករជៀរជ័ររបានទាន់ពេល។

៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានបើកកិច្ចប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋាន និងពង្រឹងការងារកសិ-ឧស្សាហកម្មនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង ២៥រាជធានី-ខេត្ត
- បានចូលរួមកិច្ចប្រជុំត្រៀមសម្រាប់កិច្ចសន្ទនាទ្វេភាគី ជប៉ុន កម្ពុជា
- បានចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពី ការលើកគម្រោងកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ដំណាក់កាលទី២
- បានចូលរួមប្រជុំការងាររៀបចំផែនការមេសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០

- ចូលរួមប្រជុំពិភាក្សាលើរបៀបវារៈប្រកាសស្តីពី (១)បែបបទ ស្លាកសញ្ញាព័ត៌មានបញ្ជាក់លើសម្បកវេចខ្ចប់គ្រាប់ពូជដំណាំ (២)ប្រកាសស្តីពីបែបបទនៃការពិន័យអន្តរការណ៍ និងតម្លៃទីផ្សារគ្រាប់ពូជ ជាំដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ (៣)ប្រកាសស្តីពីនីតិវិធីដោះស្រាយការតវ៉ា ទាក់ទងនឹងគុណភាពគ្រាប់ពូជដំណាំ

- បានចុះបណ្តុះបណ្តាលកសិករអំពីស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មដែលមានកសិករចូលរួមសរុបចំនួន ១៤០នាក់

- បានរៀបចំ និងបញ្ជូនគម្រោងចំនួនពីរ៖ (១)គម្រោងសិក្សាស្រាវជ្រាវនិងវាយតម្លៃលើគុណភាព និងសុវត្ថិភាពនៃផលិតផលធញ្ញជាតិ (២) គម្រោងសិក្សាស្រាវជ្រាវលើការវាយតម្លៃការគ្រប់គ្រងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ

- ក្រុមការងារបច្ចេកទេសនៃមន្ទីរពិសោធន៍បានដំឡើង និងធ្វើតេស្តម៉ាស៊ីន Ultra Pure Water និងម៉ាស៊ីន UV-2601

- បានចូលរួមជាអ្នកសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីប្រតិបត្តិស្តង់ដាអន្តរក្រសួងសម្រាប់ការអង្កេត និងឆ្លើយតបចំពោះការរាតត្បាតជំងឺបណ្តាលមកពីការពុលចំណីអាហារ

- បានបញ្ជូនសំណើគម្រោងទៅកាតីចិន China National Research Institute of Food and Fermentation Industries ដើម្បីគាំទ្រមន្ទីរពិសោធន៍ផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា។

៤ ផ្នែកផលិតកម្ម និងបសុព្យាបាល

៤.១ ការងារផលិតកម្ម៖ បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖

- **ការងារកែលម្អពូជ៖** មន្ត្រីជំនាញបានបន្តចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព មានការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់ ក្រោមកិច្ចសហការយ៉ាងល្អប្រសើរជាមួយដៃគូពាក់ព័ន្ធ។

- **ការងារឡជីវឧស្ម័ន៖** បន្តចុះអប់រំ ណែនាំ ផ្សព្វផ្សាយ ការអនុវត្តល្អប្រសើរក្នុងការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន៖ ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់។

- **ចំណីសត្ត៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

- **ការងារដំណាំចំណីសត្ត៖** បន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្ត ការធ្វើសួនដំណាំចំណីសត្ត ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង CIAT។

៤.២ ការងារបសុព្យាបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្ត និងផលិតផលមានដើមកំណើតពីសត្ត៖** ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ នេះ រាជធានី-ខេត្តចំនួន១៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៦ ២០៦លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្ត ទីកន្លែងចិញ្ចឹមសត្ត សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្ត។ បទល្មើសសត្ត និងផលិតផលមានដើមកំណើតពីសត្ត ត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្ត និងផលិតកម្មសត្តបានចំនួន ០៧ករណី សត្តចំនួន ១៣ក្បាល ដោយបានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ៤១៨,៣គីឡូក្រាម និងផាកពិន័យ ៩លានរៀល ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្ត រស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញ ដើម្បីការពារការឆ្លងកាលជាលនៃជំងឺផ្សេងៗ។

• **ការងារសុខភាពសាធារណៈ**៖ ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ»តាមបណ្តារាជធានី-ខេត្ត។ រហូតមកទល់ពេលនេះសត្តឃាតដ្ឋានទទួលបានគោលការណ៍អនុវត្តចំនួន ១៥៥កន្លែង និងបានចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីសុខុមាលភាពសាធារណៈ។

• **ការងារនីតិកម្មនិងវិវាទ**៖ កំពុងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្ត ទៅតាមលំដាប់អាទិភាពមានជាអាទិ៍៖ សេចក្តីព្រាងប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងអង្គភាពចំណុះនាយកដ្ឋាន និងវិទ្យាស្ថាននៃអគ្គនាយកដ្ឋានសុខភាពសត្ត និងផលិតកម្មសត្ត សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងគ្រប់គ្រងសត្តឃាតដ្ឋាន ព្រមទាំងបានប្រជុំជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំចងក្រងអនុក្រឹត្យ និងសៀវភៅសម្រាប់ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

៤.៣ ការងារស្រាវជ្រាវ៖

• **ការងារស្រាវជ្រាវបសុព្យាបាល**៖ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋាន ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី។ ជាក់ស្តែងក្នុងត្រីមាសទី១ ឆ្នាំ២០១៧នេះ វិទ្យាស្ថានបានពិនិត្យវត្ថុវិភាគសរុបចំនួន ២៧៣វត្ថុវិភាគ។

• **ការងារស្រាវជ្រាវផលិតកម្ម**៖ បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោ-ក្របីភ្នំកាម៉ៅមានគោសរុបចំនួន ១១៤ក្បាល ក្នុងនោះគោបា១ក្បាល គោប្រាម៉ាន់កាត់៦ក្បាល គោជំទង់៣៨ក្បាល គោបៅដោះ៣០ក្បាល គោកំផែងសែន៣៩ក្បាល។ ដោយឡែកនៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ៤២៧ក្បាល ក្នុងនោះជ្រូកបា ៩ក្បាល ជ្រូកមេ៦០ក្បាល កូនជ្រូក១១០ក្បាល កូនជ្រូកលក់២១០ក្បាល និងជ្រូកទុកបម្រុងចំនួន២១ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតីនិងបានផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖ ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ រួមទាំងពង្រឹងយន្តការផ្សព្វផ្សាយតាមរយៈភ្នាក់ងារសុខភាពសត្វភូមិ។

៥ ផ្នែកព្រៃឈើ

៥.១ ការងារព្រៃឈើ

- ចុះពិនិត្យវាយតម្លៃការអនុវត្តគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចចំនួន ០៧ក្រុមហ៊ុន នៅខេត្តរតនគិរី

- បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ១១កន្លែង ផ្ទៃដីសរុប ទំហំ ៩៧៦ហ.ត នៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់

- កំពុងពិនិត្យផ្ទៀងផ្ទាត់ព្រំប្រទល់តំបន់ព្រៃសហគមន៍ចំនួន ២២កន្លែង ដែលមានផ្ទៃដីសរុបទំហំ ៣០ ២២៧ហ.ត ក្នុងនោះខេត្តក្រចេះ ១៨កន្លែង មានផ្ទៃដីសរុបទំហំ ២៦ ១១៦ហ.ត មណ្ឌលគីរី០២កន្លែង មានផ្ទៃដីសរុបទំហំ ៣ ៣៨៥ ហ.ត រតនគីរីចំនួន ០១កន្លែង មានផ្ទៃដីសរុបទំហំ ៤៣២ហ.ត និងខេត្តកំពង់ធំចំនួន ០១កន្លែង ត្រូវដណ្តប់លើផ្ទៃដីទំហំ ២៩៤ហ.ត

- បានធ្វើសារពើភ័ណ្ឌប៉ាន់ស្មានធនធានព្រៃឈើក្នុងសហគមន៍ព្រៃឈើអូរចុងណាចមានផ្ទៃដីសរុបទំហំ ៩៤៤ហ.ត ឃុំពូជ្រៃ ស្រុកពេជ្រាដា សហគមន៍ព្រៃឈើពីប្រង់ក្លង់ពេសចូ មានផ្ទៃដីសរុបទំហំ ១ ១០៤ហ.ត ឃុំដាក់ជាំ ស្រុកអូររ៉ាំង ខេត្តមណ្ឌលគីរី មានសមាសភាពចូលរួមចំនួន ៤១នាក់

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនក្រុមហ៊ុននិងអតិថិជនសរុបចំនួន ១៧គ្រឿង

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន១២ និងអតិថិជន០២នាក់ ដែលមានឈើហ៊ីបមូលចំនួន ៨ ៦៤១ម^{3} ឈើអារចំនួន ៤០៥ម^{3} ឈើលេខ១ចំនួន ៨ ០០០ម^{3} កូនឈើចំនួន ៣២៣ ៦០៥ដើម អុសចម្រុះចំនួន ២៩ ៧២១ស្មែរ ជ័រទឹកចំនួន ៥៥៨តោន និងជន្លង់ម្រេចចំនួន ៦ ៥៥៥តោន។

៥.២ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវ និងអង្កេតតាមដានសត្វព្រៃនៅសហគមន៍ព្រៃឈើសង្ឆរត្ងាវ៉ន្ត គ្របដណ្តប់លើស្រុកចំនួន០៣គឺ ស្រុកអន្លង់វែង ស្រុកសំរោង និងស្រុកចុងកាល់ ក្នុងឃុំចំនួន ៥គឺ ឃុំសំរោង ឃុំកូនក្រៀល ឃុំត្រពាំងត្រាវ ឃុំរំទង ឃុំពង្រ និងភូមិចំនួន ៨គឺ ភូមិឈូក ភូមិប៉ក់នីម ភូមិថ្មី ភូមិទំបន់ថ្មី ភូមិពោលសំព័រ ភូមិចារថ្មី ភូមិចារចាស់ និងភូមិស្រះកែវ ក្នុងខេត្តឧត្តរមានជ័យ

- បំពាក់ម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ១១គ្រឿងនៅតំបន់មានវត្តមានជំរីព្រៃនៅតាមជួរភ្នំក្រវាញ ថ្មបាំង អាវ៉ែង វាលតាភូ និងអូរកីង ខេត្តកោះកុង ក្នុងគោលបំណងតាមដាន និងពិនិត្យប្រភេទសត្វព្រៃ ជាពិសេសដឹងពីស្ថានភាពសុខភាពរបស់សត្វព្រៃ បានរកឃើញជំរីចំនួន ២២ក្បាល មានលក្ខណៈរាងកាយ និងសុខភាពល្អ ក៏ប៉ុន្តែមានកូនជំរី ០១ក្បាល ឃ្លីជើង និងជំរីឈ្មោល ០១ក្បាល មានលក្ខណៈមិនប្រក្រតីនៅចុងប្រម៉ោយទំនងជាដោយសារអន្ទាក់ កត្តាគំរាមកំហែងដល់សត្វព្រៃនៅក្នុងតំបន់សិក្សាគឺការដាក់អន្ទាក់ ការឆ្លុះបណ្តើរឆ្កែ និងប្រើសាំភ្លើងកែឆ្នៃ

- ក្រុមហ៊ុនចំនួន៦ បានគ្រប់គ្រងកសិដ្ឋានចំនួន៧ ដែលមានស្វាក្តាមសរុបចំនួន ៥៥ ៤២៩ក្បាល ហើយក្នុងត្រីមាសទី១នេះផងដែរចំនួនសត្វស្វាក្តាមនាំចេញសរុបមានចំនួន ៧៦២ក្បាល។

៥.៣ កសិដ្ឋានចិញ្ចឹម ការបន្ទាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧នៅឧទ្យានសួនសត្ត និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៣២៩ក្បាល (បក្សី៥០ ប្រភេទ ថនិកសត្ត ៤៥ប្រភេទ និង ល្មូន ១៤ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៣៧០ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៧៣ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៣៤៧ ក្បាល ជួសជុលផ្លូវលុបសម្បុកមាន់ និងក្រាលក្រូសក្រហមបានប្រវែង ៥ ៥០០ម និងកាប់ឆ្លារអនាម័យព្រៃបានទំហំ ៨,៣ហ.ត។ ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខ-ជាតិអន្តរជាតិ ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ០៥គឺនៅអាវ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ(ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)។ ធ្វើការពិនិត្យតាមដាននៅតំបន់អភិរក្សដោយបានជួបប្រទះក្រពើភ្នំផ្ទាល់ចំនួន ១២ក្បាល ស្លាកស្នាម ១៧កន្លែង និងលាមកចំនួន ៣៨ដុំ បានលែងក្រពើភ្នំចំនួន ០៦ក្បាលនៅស្ទឹងកំពង់តាជ័យ ខេត្តកោះកុង ចែកប្រដាប់ក្មេងលេង ២០ឈុត និងសៀវភៅរឿងនិទានពីបរិស្ថានចំនួន ០៧ក្បាល ដល់សាលាបឋមសិក្សាភូមិពោធិ៍ជីង។

៥.៤ ការងារដាំដើមឈើ

- ការចុះសិក្សាស្រាវជ្រាវ និងធ្វើសារពើភ័ណ្ឌទីតាំងដីសម្រាប់ការងារដាំឈើ
- ការងារថែទាំចម្ការឈើចាស់
- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ២៥៩ ០០៤ដើម និងចែកជូនប្រជាពលរដ្ឋចំនួន ៣៦ ១៦៧ដើម
- ក្រុមហ៊ុនដាំឈើដែគូសហការមានក្រុមហ៊ុន ស៊ីងបាយអូរថេក ដែលជាក្រុមហ៊ុនកូរ៉េបានឈូសឆាយដីបានចំនួន ៣០០ហ.ត ត្រៀមដាំដុះនៅដើមរដូវភ្លៀងខាងមុខ។

៥.៥ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យទីតាំងរោងម៉ាស៊ីនអារ-កែច្នៃឈើតាមលក្ខណៈបច្ចេកទេសលើក្រុមហ៊ុនចំនួន ១១សុំបន្តសុពលភាព និងក្រុមហ៊ុនចំនួន ០១ស្នើសុំបង្កើត

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុន Y.C.T មានផលិតផលរានទេវតាចំនួន ៨៩ម^{3}១៩៤ ក្រុមហ៊ុន វ៉ី អេនើជី ឡូជីស្ទីក មានផលិតផលឈើលេខ១ចំនួន១០៣ម^{3} និងក្រុមហ៊ុន រ៉ ហ្ស៊ីន រ៉ីល ភ៉ាយ មានជ័រទឹកសរុបចំនួន ៤៥តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលឈើចំនួន ០៤ក្រុមហ៊ុនប្រភេទឈើ Radiata ឈើMDF Umbila និង CHANFUTA ពីប្រទេសញ្ញូហ្ស្សាលែន កូរ៉ា មូហ្ស៊ាំប៊ិច និងចិន មានបរិមាណសរុប ៥១៦ម^{3}

- បានចូលរួមកិច្ចប្រជុំចំនួន ៥លើកដែលផ្តោតសំខាន់ដូចជា៖(១)ការរៀបចំកម្មវិធីវិនិយោគព្រៃឈើ (២)ការអនុវត្តគម្រោងស្តារតំបន់ទេសភាពព្រៃឈើ (៣)ផែនការវិនិយោគព្រៃឈើ (៤)ការរៀបចំគម្រោងសិក្សាតម្លៃសេដ្ឋកិច្ចនិងជីវសាស្ត្រក្នុងតំបន់គ្រប់គ្រងព្រៃឈើ (៥)គម្រោងគ្រប់គ្រងតំបន់ទេសភាពតំបន់ជួរភ្នំក្រវាញ។

៥.៦ ការចារចំណូលព្រៃឈើ

- សម្រាប់ត្រីមាសទី១ឆ្នាំ២០១៧នេះ ចំណូលពីថ្លៃលួយសារផលអនុផលព្រៃឈើសរុបចំនួន ៥ ៥៧៦ ៩៤១ ៣២៩រៀល និងចំណូលពីសេវាសាធារណៈចំនួន ៩២១ ៥៥១ ៦៨៤រៀល និង២៧ ០៨៥,៨៧ដុល្លារអាមេរិក។

៥.៧ ការចារនីតិកម្មនិងវិវាទ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន ៣៧០ករណី ដោយបញ្ជូនទៅតុលាការចំនួន ២៦៨ករណីនិងពិន័យអន្តរការណ៍ចំនួន ១០២ករណី

- ដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន ១១២ម^{3} ឈើអារចំនួន ៨៦៥ម^{3} ឈើគ្រាក់ក្រញូងចំនួន ១៧ម^{3} និង៥៤០គ.ក្រ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ៤៦៣ក្បាល និង៣៧៧គ.ក្រ អនុផលព្រៃឈើនិងសម្ភារផ្សេងៗមួយចំនួនទៀត និងសំណុំរឿងបទល្មើសកាប់រានដីព្រៃចំនួន ១៥ករណី មានផ្ទៃដីព្រៃឈើដែលតាប់រានចំនួន៤៧០ហ.ត ព្រមទាំងបានបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី និងចុះពង្រឹងការអនុវត្តច្បាប់ចំនួន ២១លើក

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ (Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប។

៦ ផ្នែកជលផល

៦.១ អាជីវកម្មនេសាទ

៦.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម អនុវត្តបានចំនួន ៨ ៩៤៥គោន ស្មើនឹង៤១,២១% នៃផែនការ ១២ ០០០គោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២ ០១៦ កើនឡើងចំនួន ៣ ៨៩៥គោន

- នេសាទត្រីសារក្នុងដែននេសាទ អនុវត្តបានចំនួន ៦៩ ៩៥០គោន ស្មើនឹង២០,៣៣% នៃផែនការ ៣៤៤ ០០០គោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០ ១៦ កើនឡើងចំនួន ១ ៩៥០គោន

- នេសាទត្រីសារតាមវាលស្រែ អនុវត្តបានចំនួន ១៩ ៥០០គោន ស្មើនឹង១៣,៥៤% នៃផែនការ ១៤៤ ០០០គោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៥០០គោន។

៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ២៥ ៣២៥គោន ស្មើនឹង២៣,០២% នៃផែនការ ១១០ ០០០គោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១ ៤ ៧៥គោន។

៦.២ ទារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា អនុវត្តបានចំនួន ២៩ ៩៧៨គោន ស្មើនឹង១៤,៤៦% នៃផែនការ ២០៧ ៣៦០គោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០ ១៦ កើនឡើងចំនួន ៤ ៤២៨គោន

- ការចិញ្ចឹមក្រពើ អនុវត្តបានចំនួន ២៧ ៥០០ក្បាល ស្មើនឹង១១,០០% នៃផែនការ ២៥០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៥០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួនប្រមាណ ៤៤ ៨០០ ០០០កូន ស្មើនឹង២២,៤០% នៃផែនការ ២០០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០ ១៦ កើនឡើងចំនួនប្រមាណ ១២ ៨០០ ០០០កូន។

៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ អនុវត្តបានចំនួន ១៧ ៣៥០តោន ស្មើនឹង២១,១៦% នៃផែនការ ៨២ ០០០ តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ១៥០តោន

- ផលនេសាទសមុទ្រ អនុវត្តបានចំនួន ២ ៥៣០តោន ស្មើនឹង៣១,៦៣% នៃផែនការ ៨ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ១០ ៩០០ ០០០លីត្រ ស្មើនឹង២១,៨០% នៃផែនការ ៥០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៨០០ ០០០លីត្រ។

៦.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ អនុវត្តបានចំនួន ២ ៥៣០តោន ស្មើនឹង១៦,៨៧% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ថយចុះចំនួន ៥០តោន

- ផលនេសាទកែច្នៃ អនុវត្តបានចំនួន ១ ៣៧០តោន ស្មើនឹង២៧,៤០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ ថយចុះចំនួន ១៥០តោន។

៦.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ១ ០៥៩ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ០២៧ករណី និងសមុទ្រចំនួន ៣២ករណី

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង ៥៨១ ០៩០ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន ៦ ៥២២មាត់ បង្គោល/ចម្រឹងចំនួន ៣៣០ ៦៦៧ដើម ឧបករណ៍ឆក់ត្រីចំនួន ២០៨គ្រឿង របាំងព្រួលប្រវែង ៣ ៨៦២ម៉ែត្រ សម្រាស់ទំហំ ៣០ ៥២៦ម៉ែត្រក្រឡា និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ២២ ៥៩៦ គ.ក្រ និងពិន័យអន្តរការណ៍ចំនួន ២៨ករណី ស្មើនឹងទឹកប្រាក់ចំនួន ១៣០ ៣០០ ០០០រៀល

- បានផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន ៥៩វគ្គ ដោយមានអ្នកចូលរួមចំនួន ២ ៣៥៦នាក់។

- គួរកត់សម្គាល់ថា ក្នុងការចុះបង្ក្រាបបទល្មើសនេសាទនៅជុំវិញបឹងទន្លេសាបគឺមានការអញ្ជើញចូលរួមចុះត្រួតពិនិត្យផ្ទាល់យ៉ាងសកម្មពី សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី ស ខេង រួមទាំងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៦.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផលសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧ ចំនួន ៨២៩ ២៩៥ ០០០ រៀល ស្មើនឹង ២៦,០៦% នៃផែនការ ៣ ១៨២ ១២៥ ៤០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ២៧២ ៥៦៥ ០០០រៀល។

៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានធ្វើពិសោធន៍ចំនួន៤៥ប្រភេទ នៅ១៧០កន្លែង ដែលនៅក្នុងនោះមានពិសោធន៍បន្សុំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន១០៦កន្លែង

- បានធ្វើពិសោធន៍ជ្រើសរើសស្រឡាយស្រូវនិងដំណាំផ្សេងៗចំនួន ២៤០ស្រឡាយ

- បានដាំពង្រីកស្រឡាយពូជដំណាំចំនួន ០៨ប្រភេទមានស្រឡាយស្រូវសរុបចំនួន ៧២ស្រឡាយ

- បានពិសោធន៍ស្តីពីឥទ្ធិពលនៃរបបទឹកផ្សេងគ្នាទៅលើការដុះលូតលាស់និងទិន្នផលដំណាំពោតក្នុងលក្ខខណ្ឌដីខ្សាច់ចំនួន ០១ពិសោធន៍

- បានពិសោធន៍តាមដានប្រសិទ្ធភាពថ្នាំកសិកម្មដើម្បីកម្ចាត់មមាចត្នោតនៅក្នុងលក្ខខណ្ឌផ្ទះកញ្ចាក់ និងកំពុងចុះប្រមូលមមាចត្នោតនៅតាមស្រែកសិករសម្រាប់ចិញ្ចឹមដើម្បីធ្វើពិសោធន៍ ព្រមទាំងបានដាំស្រូវជាចំណីមមាចត្នោត កំពុងធ្វើការសិក្សាប្រភេទថ្នាំកម្ចាត់មមាចត្នោតដែលត្រូវប្រើក្នុងពិសោធន៍និងកំពុងរៀបចំដាំពូជស្រូវក្នុងផើង

- បានប្រមូលសំណាកជំងឺសំខាន់ៗដែលកំពុងបំផ្លាញលើដំណាំស្រូវនិងស្វាយ នៅតាមដំណាក់កាលលូតលាស់របស់ដំណាំនិងកំណត់នូវវិធីសាស្ត្រនៅក្នុងលក្ខខណ្ឌមន្ទីរពិសោធន៍ និងកំពុងរៀបចំផែនការចុះពិនិត្យ តាមដាននិងវាយតម្លៃកម្រិតបំផ្លាញពីភ្នាក់ងារបង្កជំងឺលើដំណាំស្រូវនិងស្វាយនៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺ

- បានពិសោធន៍តាមដានប្រសិទ្ធភាពនៃថ្នាំកម្ចាត់ផ្សិតផ្សេងៗគ្នាលើការកម្ចាត់ជំងឺខ្ទារអំបោះត្នោតនៅលើពូជស្រូវសែនពិដោរនៅក្នុងលក្ខខណ្ឌផ្ទះសំណាញ់ ចុះប្រមូលសំណាកជំងឺខ្ទារអំបោះត្នោតលើដំណាំស្រូវនៅខេត្តតាកែវ ព្រៃវែង និងខេត្តកំពង់ធំ

- បានវិភាគសំណាកដីចំនួន៥៨សំណាក លើ pH, EC, OC, OM, N, P, K, Ca, Mg, Na និងវាយនភាពដី

- គេហទំព័រ http://www.cardi.org.kh និង http://crkb.org.kh: ក្នុងរយៈពេលមួយត្រីមាសទី១ ឆ្នាំ២០១៧នេះមានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៧៦ ៩០៨នាក់ ហើយគិតជាមធ្យមមានប្រមាណ៨៥៨នាក់/ថ្ងៃ

- បានបញ្ចប់ការបញ្ចូលនិងវិភាគទិន្នន័យពិសោធន៍ទាំងអស់ដែលបានធ្វើនារដូវវស្សាឆ្នាំ២០១៦កន្លងមក

- បានបន្តថែទាំ តាមដាននិងស្រង់ទិន្នន័យរាល់ការងារពិសោធន៍នារដូវប្រាំង២០១៦-២០១៧ ព្រមទាំងបញ្ចូលទិន្នន័យនិងធ្វើការវិភាគជាបណ្តើរៗរាល់ពិសោធន៍ណាដែលចប់សព្វគ្រប់។

៨ ផ្នែកនីតិកម្មកសិកម្ម

៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជីកាសម្ភារកសិកម្មបានចំនួន ១៦ក្រុមហ៊ុន សរុបចំនួន ២២៧មុខ
- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មសម្ភារកសិកម្មបានចំនួន ០៣ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៣ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្ទត់ផ្ទង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ០៨ក្រុមហ៊ុន។

៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំចុះបញ្ជីកាចំនួន ០៥ក្រុមហ៊ុនសរុបចំនួន ២២សំណាក។

៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី និងខេត្តកំពង់ឆ្នាំង ដែលមានសមាសភាពចូលរួមសរុបចំនួន ១១៨នាក់។

៨.៤ ការងារអនុវត្តច្បាប់

- បានធ្វើប្រតិវេទន៍ដល់ក្រុមហ៊ុនចំនួន ១២ក្រុមហ៊ុន
- ពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៩ ០០០ ០០០រៀល ពីក្រុមហ៊ុនចំនួន ០៧ អាជីវករលក់ដុំ និងលក់រាយចំនួន ០២ដេប៉ូ។

៩ ផ្នែករដ្ឋបាល

- ក្នុងត្រីមាសទី១ ឆ្នាំ២០១៧នេះ បានទទួលលិខិតពីក្រសួង-ស្ថាប័ននានាចំនួន ៩៥៨ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ១ ០២៧ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៨៩០ច្បាប់ និងចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ២ ៨៨៣ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ២៣៨ច្បាប់ ចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទចំនួន ០៦២ច្បាប់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំ ពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អប្រសើរ ព្រមទាំងចាក់ចែងផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម) ។

១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៨៥៨នាក់ ក្នុងនោះនារីចំនួន ១ ៥១៦នាក់ ស្មើនឹង ២២% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៧៦៨នាក់ ក្នុងនោះនារីចំនួន ៧៦៩នាក់ ស្មើនឹង ២៧%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន ៤ ០៩៨នាក់ ក្នុងនោះនារីចំនួន ៧៤៨នាក់ ស្មើនឹង ១៨% (បានបញ្ចូលមន្ត្រីខណ្ឌរដ្ឋបាលព្រៃឈើ(៩០០នាក់) និងខណ្ឌរដ្ឋបាលជលផល(៥០៥នាក់) ទៅក្នុងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីខេត្តរួចហើយ)
- បានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលការកិច្ចមន្ត្រីរាជការ សរុបមានចំនួន១៤១នាក់ នារី៣២នាក់
- បានចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌ មានចំនួន១៣នាក់ ក្នុងនោះបោះបង់ការងារចំនួន ០៥នាក់ សុំលាឈប់ពីការងារចំនួន ០៨នាក់ និងមរណភាពចំនួន ០៨នាក់
- បានចេញប្រកាសផ្ទេរមន្ត្រីរាជការក្រៅក្រសួងចំនួន ១០នាក់ ក្នុងនោះផ្ទេរចេញចំនួន០៨នាក់ និងផ្ទេរចូលចំនួន ០២នាក់ ផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួង មានចំនួន៣៦នាក់ ក្នុងនោះ ផ្ទេរចេញចំនួន ១៧នាក់ ផ្ទេរចូលមានចំនួន១៩នាក់
- ត្រៀមរៀបចំប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ដែលក្រសួងមុខងារសាធារណៈបែងចែកឲ្យមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន ១៨៨នាក់
- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារមានចំនួន ១៩នាក់ ក្នុងនោះមាន៖ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំមានចំនួន០៨នាក់ ច្បាប់ព្យាបាលជំងឺមានចំនួន ០៣នាក់ និងច្បាប់សម្រាកមាតុភាពមានចំនួន០៨នាក់
- បានរៀបចំធ្វើប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីកសិកម្ម អង្គភាពថ្នាក់កណ្តាល និងរាជធានីខេត្ត
- បានពិនិត្យ កែតម្រូវលើការប្រែប្រួលស្ថានភាពរដ្ឋបាលពីខែមករា ដល់ខែឧសភា ឆ្នាំ២០១៧
- បានចេញប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សមានចំនួន៤៧នាក់ ក្នុងនោះនារី០៧នាក់
- បានចេញប្រកាសឲ្យមន្ត្រីរាជការ ចូលបម្រើការងារនៅអង្គភាពដើមវិញមានចំនួន២៧នាក់ ក្នុងនោះនារី០៨នាក់
- បានចេញប្រកាសដាក់មន្ត្រីឲ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈមានចំនួន ៣២នាក់
- បានបែងចែកមន្ត្រីជាប់កិច្ចសន្យាសម្រាប់ប្រើប្រាស់ឆ្នាំ២០១៧ នៅអង្គភាពថ្នាក់កណ្តាល និងរាជធានីខេត្តចំនួន ១០២៨នាក់
- បានចេញប្រកាស ស្តីពីការអនុញ្ញាតឲ្យជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឆ្នាំ២០១៧ សម្រាប់ប្រើប្រាស់នៅអង្គភាពថ្នាក់កណ្តាល ចំនួន៦៣០នាក់
- មន្ត្រីរាជការបានចូលរួមការងារបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស សរុបមានចំនួន ៤៦៨នាក់ ក្នុងនោះនារី១៥៨នាក់។

១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានធ្វើសវនកម្មចំនួន ១៣អង្គភាព និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានធ្វើការប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះឆ្នាំ២០១៦
- បានធ្វើការវាយតម្លៃអង្គភាពតាមលក្ខខណ្ឌវិនិច្ឆ័យអង្គភាពថវិការបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- បានចេញលិខិតណែនាំឱ្យពង្រឹងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង

- បានធ្វើផែនការសកម្មភាពលម្អិត និងផែនការថវិកាឆ្នាំ២០១៧ ដើម្បីអនុវត្តសកម្មភាពរួមដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

១២ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

១២.១ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ សរុបចំនួន ៨៧៨នាក់ (ស្ត្រី ៣១២នាក់) ក្នុងនោះ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៦២១នាក់(ស្ត្រី ២១៦នាក់) និងនិស្សិតថ្នាក់បរិញ្ញារងចំនួន ២៥៧នាក់(ស្ត្រី ៩៦នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្ត សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានបន្តការរៀបចំគុណភាពអប់រំទៅតាមលក្ខណៈវិនិច្ឆ័យទាំង៩របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា

- បានបន្តការកែតម្រូវកម្មវិធីសិក្សាឱ្យឆ្លើយតបនឹងទីផ្សារ បទដ្ឋានជាតិ អន្តរជាតិ

- បានចុះអនុស្សរណៈយោគយល់គ្នារវាងសាលាជាតិកសិកម្មព្រែកលៀប និងសាកលវិទ្យាល័យបច្ចេកវិទ្យា Rajamangala Isan ប្រទេសថៃ និងសាកលវិទ្យាល័យកសិកម្ម BOGOR នៃប្រទេសឥណ្ឌូនេស៊ី

- បានដឹកនាំគណៈប្រតិភូនៃសាកលវិទ្យាល័យបច្ចេកវិទ្យា Rajamangala Isan ប្រទេសថៃចុះទស្សនកិច្ចសិក្សានៅខេត្តព្រះសីហនុ ដើម្បីស្វែងរកឱកាសការងារសហការផ្នែកអប់រំ និងស្រាវជ្រាវ

- បន្តជួសជុលអគារសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន និងថ្នាក់វិទ្យាសាស្ត្រមូលដ្ឋាន និងបរិស្ថានចំនួន ០២ខ្នង

- បានចុះអនុស្សរណៈយោគយល់គ្នារវាងសាលាជាតិកសិកម្មព្រែកលៀបនិងសាកលវិទ្យាល័យ Hohai នៃប្រទេសចិន

- បានចុះត្រួតពិនិត្យសម្ភារ និងគ្រឿងប្រើប្រាស់នៅស្ថានីយពិសោធន៍កសិកម្មក្រាំកក់

- បានបន្តរៀបចំពិសោធន៍ដំណាំស្រូវជប៉ុន និងដំឡូង

- បានចូលរួមសិក្ខាសាលាស្តីពី៖ (១) ការសន្សំសំចៃទឹកក្នុងវិស័យកសិកម្មសម្រាប់កសិករនៅតាមដងទន្លេមេគង្គ (២) ប្រព័ន្ធដីវឧស្ម័នខ្នាតធំ និង(៣) ការបង្កើតមគ្គុទេសក៍សម្រាប់ការប្រើប្រាស់តំបន់ដីសើមដោយឈ្លាសវៃ។

១២.២ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៦-២០១៧ សរុបមានចំនួន ៧៨៦នាក់(ស្ត្រី ៣១៨នាក់) រួមមាន៖ និស្សិតអាហារូបករណ៍សរុប ៥៧៧នាក់ (ស្ត្រី ២៧១នាក់) និស្សិតសិក្សាបង់ថ្លៃចំនួន ២០៩នាក់ (ស្ត្រី ៤៧នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្ត វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីស្វែងរកជំនួយ ក្នុងនោះកំពុងសហការជាមួយ DTRA ICEBP ដើម្បីរៀបចំមន្ទីរពិសោធន៍សត្ត និងបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍

- បានសហការជាមួយអង្គការ OISCA បញ្ជូននិស្សិតជំនាញក្សេត្រសាស្ត្រចំនួន ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំនៅប្រទេសជប៉ុន

- បានសហការជាមួយទីភ្នាក់ងារ KOICA ដើម្បីផ្តល់អាហារូបករណ៍សម្រាប់សាស្ត្រាចារ្យទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅប្រទេសកូរ៉េ

- បានជួបពិភាក្សាជាមួយប្រតិភូសាកលវិទ្យាល័យ វ៉ាស៊ីនតោន ស្តីពីការរៀបចំសិក្សាគម្រោងចិញ្ចឹមគោយកទឹកដោះ នៅខេត្តកំពង់ចាម

- បានទទួលជួបតំណាង JICA ពិភាក្សាពីគម្រោងសិក្សាអង្កេតពីភាពរីកចម្រើននៃសហគមន៍កសិកម្ម ដែលមានទីតាំងនៅជុំវិញខេត្តកំពង់ចាម

- បានបន្តសហការជាមួយ DTRA (Defence Threat Reduction Agency) បើកវគ្គបណ្តុះបណ្តាលនិស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្ត

- បានរៀបចំពិសោធន៍បន្សុទ្ធពូជពោតដំណើបក្នុងស្រុក នៅច្បារពិសោធន៍

- បានចុះសិក្សាជំងឺលើដំណាំម្រេចនៅឃុំជុប ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ

- ធ្វើការបង្ការពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម

- បន្តពិសោធន៍ចិញ្ចឹមនិងភ្ញាស់ដង្កូវនាងព្រៃ និងបញ្ជូនដង្កូវនាងព្រៃឱ្យសហគមន៍កសិកម្មចិញ្ចឹមចំនួន ១០គ្រួសារ នៅឃុំសូភាស ស្រុកស្ទឹងត្រែង ខេត្តកំពង់ចាម។

១២.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៦-២០១៧ សរុបមានចំនួន ៣ ៦៣៥នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្ត្ว ជីវជ្ជសាស្ត្រសត្ត្ว វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និង មហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង និងថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានបញ្ជូនមន្ត្រីសាស្ត្រាចារ្យចំនួន៩រូប ចូលរួមកិច្ចប្រជុំនិងសន្និសីទវិទ្យាសាស្ត្រផ្សេងៗ និង០៥រូបផ្សេងទៀតចូលរួមវគ្គបណ្តុះបណ្តាលខ្លី រយៈពេលពី១សប្តាហ៍រហូតដល់៦ខែ នៅសាកលវិទ្យាល័យដៃគូនៅបរទេស ព្រមទាំងបានសហការជាមួយអង្គការ SEARCA និង គម្រោង HEQCIP បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការវ័យក្មេងចំនួន១៨នាក់ នៅខេត្តសៀមរាប ដើម្បីពង្រឹងសមត្ថភាពលើកគម្រោងសំណើស្រាវជ្រាវ សម្រាប់ការអភិវឌ្ឍន៍កសិកម្មនិងជនបទ

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយអង្គភាពបីគឺ៖ ១.វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា(ITC) ស្តីអំពីការបង្កើតនិងប្រើប្រាស់ធនធានសិក្សាអេឡិចត្រូនិក ជាមួយសាកលវិទ្យាល័យកសិកម្មបូហ្គ ២.ប្រទេសឥណ្ឌូនេស៊ី (Bogor Agriculture University) ស្តីអំពីការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ និងការស្រាវជ្រាវរួមគ្នា ៣.ជាមួយអង្គការ KOPIA និងRotary International Club ស្តីពីការគាំទ្រដល់កម្មវិធីចិញ្ចឹមមាន់និងការដោះស្រាយជីវភាពគ្រួសារ

- បានទទួលគណៈប្រតិភូបរទេស គ្រូនិងអ្នកជំនាញពីអឺរ៉ុបមកបំពេញបេសកកម្មនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីគាំទ្រដល់សកម្មភាពកិច្ចសហប្រតិបត្តិការគាំទ្រគម្រោង និងជំនាញជីវជ្ជសាស្ត្រសត្ត្ว ព្រមទាំងបានទទួលនិស្សិតនិងសាស្ត្រាចារ្យមកពីសាកលវិទ្យាល័យ Shinshu ប្រទេសជប៉ុន ដើម្បីប្រជុំពិភាក្សារៀបចំកម្មវិធីកម្មសិក្សានៅទីវាល និងការស្រាវជ្រាវរួមគ្នា

- មន្ត្រីសាស្ត្រាចារ្យ និង និស្សិតបានបរិច្ចាកឈាមជូនមជ្ឈមណ្ឌលជាតិផ្តល់ឈាមបានចំនួន ២២២នាក់ និស្សិតនារីនៃមហាវិទ្យាល័យកសិឧស្សាហកម្មមួយរូប បានទទួលពានរង្វាន់អ្នកវិទ្យាសាស្ត្រវ័យក្មេង YES ពីក្រុមហ៊ុនហុងដាកម្ពុជា

- បានពិភាក្សាជាមួយសាកលវិទ្យាល័យ Hokkaido ស្តីពីកិច្ចសហការរវាងសាកលវិទ្យាល័យទាំងពីរលើកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស និងបានពិភាក្សាលើកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យបច្ចេកវិទ្យា King Mongkhut នៃប្រទេសថៃលើការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជា

- បានបញ្ជូនមន្ត្រី១រូបទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅប្រទេសអូស្ត្រាលី និងបានបញ្ជូនមន្ត្រីចំនួន ៨នាក់ចូលរួមកម្មវិធីផ្លាស់ប្តូរមន្ត្រីសាស្ត្រាចារ្យនៅសហគមន៍អ៊ីរ៉ុប

- បានបញ្ជូននិស្សិត៣រូបទៅចូលរួមកម្មវិធីផ្លាស់ប្តូរនិស្សិតនៅសាកលវិទ្យាល័យ Granada នៃប្រទេសអេស្ប៉ាញ និងបន្តការសិក្សាថ្នាក់បរិញ្ញាជាន់ខ្ពស់នៅប្រទេសជប៉ុន

- បានរៀបចំពិធីសំណេះសំណាលនិស្សិតចំនួន ២៥០នាក់ដែលមានបំណងចូលរួមកម្មសិក្សាឆ្នាំ២០១៧ នៅប្រទេសអ៊ីស្រាអែល ជាមួយលោកនាយក Agrostudies ។ និស្សិតចំនួន៧៥នាក់បានប្រារព្ធពិធីដាំដើមឈើតាមវិធីសាស្ត្រជប៉ុនបានចំនួន២០០០ដើម នៅក្នុងបរិវេណសាកលវិទ្យាល័យ។

IV-សេចក្តីសន្និដ្ឋាន និងទាយតម្លៃ

មកទល់ពេលនេះ ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបាន ៥១៨ ៥១៨ហ.ត ស្មើនឹង ៩៩.៩៩% នៃផ្ទៃដីអនុវត្តបាន ៥១៨ ៥៧៨ហ.ត។ ដោយឡែក ទិន្នផលស្រូវប្រាំងគិតជាមធ្យមទទួលបានចំនួន ៤,៤៦៥តោន/ហ.ត លើសឆ្នាំមុនចំនួន ៤៣គ.ក្រ/ហ.ត។ ជាមួយនឹងការខិតខំប្រមូលផលដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់បងប្អូនកសិករ ក្រសួងកសិ

បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវប្រាំង ដោយគិតគូរទៅលើយន្តការនិងបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងករណីមានគ្រោះរាំងស្ងួត ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្ត និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ទន្ទឹមនឹងនេះ ក៏បានជំរុញចាត់វិធានការណែនាំក្នុងការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ ព្រមទាំងបានចេញសេចក្តីណែនាំទៅដល់អង្គភាពជំនាញក្រោមឱវាទសហការជាមួយគ្រប់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃ និងភ្លើងឆេះស្រូវជាយថាហេតុក្នុងរដូវប្រាំងនេះ។ ជាមួយនេះ ក្រសួងបានយកចិត្តទុកដាក់បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន រួមទាំងសហគមន៍កសិកម្មផងដែរក្នុងក្របខ័ណ្ឌក្រុមការងារទី៩ ដើម្បីរិះរកវិធានការតាមភារកិច្ចក្នុងការចូលរួមដោះស្រាយរាល់បញ្ហាប្រឈមលើការធ្លាក់ចុះតម្លៃស្រូវអង្ករនៅមូលដ្ឋាន។ ព្រឹត្តិការណ៍សំខាន់មួយទៀតគឺ ការរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីជួបជ្ជាល់ជាមួយផលិតករ សហគមន៍កសិកម្ម និងតួអង្គពាក់ព័ន្ធផ្សេងៗទៀតដែលមានអ្នកចូលរួមប្រមាណ ៥០០នាក់ ដើម្បីស្វែងយល់ និងដោះស្រាយរាល់បញ្ហាប្រឈមក្នុងការអភិវឌ្ឍវិស័យកសិកម្មឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីម្រៅរបស់រាជរដ្ឋាភិបាល។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្ត បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យនិងកូតគាមអនាម័យកាមច្រកសំខាន់ៗនៅតាមព្រំដែន ដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានជំរុញគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយឱ្យបានទាន់ពេលវេលាលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗតាមអនុវិស័យនីមួយៗ ។ ជាពិសេស បន្តយកចិត្តទុកដាក់ពង្រឹងការផ្ទេរមុខងាររបស់ខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលទៅថ្នាក់ក្រោមជាតិឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក្នុងក្របខ័ណ្ឌកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្មដំណើរការនៃកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការតាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរថ្នាក់ក្រោមជាតិ។

V- ទិសដៅអនុវត្តបន្ត

១ ផ្នែកដាំដុះ :

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវប្រាំង និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៦-២០១៧ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម ព្រមទាំងចេញសេចក្តីណែនាំឱ្យមានការប្រុងប្រយ័ត្នក្នុងការចូលរួមទប់ស្កាត់ភ្លើងឆេះព្រៃ និងឆេះស្រូវជាយថាហេតុ

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវទាន់ពេលវេលា ចាត់ចែងជាបន្តក្នុងការរៀបចំក្រុមការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រូវអង្ករនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ

- យកចិត្តទុកដាក់គិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ និងការនាំចេញកសិផលទៅក្រៅប្រទេស

- បន្តកិច្ចសហការក្នុងការរៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័ល

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លួនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

២ ផ្នែកផលិតកម្មនិងបសុព្យាបាល :

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាត់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្ព ការធ្វើអនាម័យសត្ព ការព្យាបាល សង្គ្រោះសត្ព និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្ពដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្ពនៅតាមបណ្តាខេត្ត-រាជធានី និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្ពគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ ជាពិសេសការចិញ្ចឹមសត្ពជាលក្ខណៈគ្រួសារនៅតាមតំបន់ដែលខ្សត់ទឹក

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្ពតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្ពនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្ពនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូ

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះកាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្ពនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី។

៣ ផ្នែកព្រៃឈើ :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្តុកភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយ

ដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផលអនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរងវិលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើសំខាន់ៗ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់ព័ន្ធនានាជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២ និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព

- ចុះពិនិត្យទីតាំងដើម្បីត្រៀមរៀបចំរុក្ខទិវានាពេលខាងមុខ។

៤ ផ្នែកជលផល:

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ព្រមទាំងគិតគូរអំពីមធ្យោបាយសង្គ្រោះធនធានមច្ឆជាតិនៅពេលឡើងកម្តៅខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

- រៀបចំផ្ទ្រាំងភ្លើង និងប៉ាមយ៉ាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក

- បន្តបង្កើត និង ពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ធំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៧ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទជាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គា ក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្ពោឱ្យបានសមស្របតាមវិធានបច្ចេកទេស ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ

- ចុះពិនិត្យទីតាំងដើម្បីត្រៀមរៀបចំមច្ឆទិវានាពេលខាងមុខ។

៥ ផ្នែកពាក់ព័ន្ធផ្សេងៗ :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាម

រាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជីកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- បន្តសហការរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផល ព្រមទាំងជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ផ្សេងៗទៀត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រតាមការចាំបាច់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទ ការចុះពង្រឹងការកិច្ចក្នុងការបញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផល ឱ្យស្ថិតក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ត្រៀមរៀបចំទិវាពិភពលោកប្រយុទ្ធប្រឆាំងនិងហោស្ថានកម្ម ឬឯនភាពដ៏ដែលនឹងប្រព្រឹត្តិទៅនាថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៧

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា រួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលវប្បកម្មមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើតសិតម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុ-អាកាស ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូប-នីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

ភ្នំពេញ, ថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

យុទ្ធ ភូថង